# ផែនការមេលើកទី ២
# ស្តីពី
# សុខភាព និងសុវត្ថិភាពការងារ
# ឆ្នាំ ២០១៨-២០២២

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ឧបត្ថម្ភដោយៈ អង្គការអន្តរជាតិខាងការងារ

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា បន្តរក្សាបាននូវសន្តិភាព ស្ថិរភាព ការទាក់ទាញបាននូវវិនិយោគិនកាន់តែល្អ និងកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងរយៈពេល ២ ទសវត្សរ៍កន្លងមកនេះ នាំឱ្យយើងអាចបន្តរក្សាបាននូវការងារដែលមានស្រាប់ និងបង្កើតការងារបន្ថែមសរុបចំនួន ៣.៦ លាន នៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម និងចំនួន ០.៧ លាន នៅក្នុងវិស័យកសិកម្ម។ កត្តានេះនាំឱ្យកម្ពុជាយើងក្នុងពេលបច្ចុប្បន្ន មានអត្រាមានការងារធ្វើខ្ពស់រហូតដល់កម្រិត៩៩.៣% ស្មើនឹងប្រមាណជិត ១០ លាននាក់ ហើយអត្រាគ្មានការងារធ្វើត្រូវបានកាត់បន្ថយមកត្រឹម កម្រិតទាប ០.៧%។ ក្នុងចំណោមអ្នកមានការងារធ្វើសរុបទាំងអស់ មានចំនួនជិត ១.៥ លាននាក់ ធ្វើការនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ចំនួនជាង ២.៤ លាននាក់ នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ចំនួនជាង៤ លាននាក់នៅក្នុងវិស័យកសិកម្ម ចំនួន ១.២ លាននាក់ ធ្វើការនៅក្រៅប្រទេស និងចំនួនជាង០.៥ លាននាក់ជាមន្ត្រីសាធារណៈ។

បន្ថែមលើការយកចិត្តទុកដាក់លើការបង្កើតការងារថ្មីកាន់តែល្អ និងផ្តល់ការអភិវឌ្ឍជំនាញបន្ថែមជូនប្រជាពលរដ្ឋ រាជរដ្ឋាភិបាលបានងាកមកផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការដំឡើងប្រាក់ឈ្នួលអប្បបរមា និងពង្រីក និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គម សុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ ដើម្បីធានាឲ្យកាន់តែបាននូវស្ថិរភាព សន្តិសុខ និងនិរន្តភាពការងារ និងប្រាក់ចំណូល និងភាពកក់ក្តៅក្នុងចិត្តរបស់កម្មករនិយោជិត។ សុខភាព និងសុវត្ថិភាពការងាររបស់កម្មករនិយោជិត គឺជាការងារអាទិភាពមួយទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលត្រូវយកចិត្តទុកដាក់ខ្ពស់លើគ្រប់សកម្មភាព ជាពិសេសការពង្រឹងប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារនៅកន្លែងធ្វើការ សំដៅការពារកម្លាំងពលកម្មជាតិ ចាប់ពីថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត រហូតដល់ថ្នាក់សហគ្រាស គ្រឹះស្ថាន ដែលជាមូលដ្ឋានចុងក្រោយនៃប្រព័ន្ធ។ បន្ទាប់ពីបានអនុវត្តប្រកបដោយជោគជ័យនូវផែនការមេលើកទី១ ស្តីពីសុខភាព និងសុវត្ថិភាពការងារឆ្នាំ២០០៩-២០១៣ ផែនការមេលើកទី២នេះ ត្រូវបានរៀបចំឡើងដោយមានការសិក្សាផ្អែកលើលទ្ធផលនៃការអនុវត្តផែនការមេលើកទី១ ការពិគ្រោះយោបល់ត្រីភាគី ការចូលរួមពីភាគី និងអ្នកពាក់ព័ន្ធផ្សេងៗរួមទាំងមន្ត្រីក្រោមឱវាទនាយកដ្ឋានពេទ្យការងារ និងអង្គការអន្តរជាតិខាងការងារ ដែលបានឯកភាព និងសម្រេចដាក់ចេញនូវសកម្មភាពជាអាទិភាព ចំនួន៦ សម្រាប់ចង្អុលបង្ហាញដល់គ្រប់ភាគីពាក់ព័ន្ធ យកទៅពង្រីកផែនការសកម្មភាពសំដៅបង្កើនប្រសិទ្ធភាពការងារនៅក្នុងវិស័យសុខភាព និងសុវត្ថិភាពការងារឱ្យស្របតាមការវិវត្តន៍នៃសង្គមសេដ្ឋកិច្ចសម្រាប់ កម្មករនិយោជិតនៅគ្រប់មុខវិជ្ជាជីវៈ។

ផែនការមេលើកទី២នេះ បំពេញតួនាទីជាផែនទីបង្ហាញផ្លូវ និងកាលានុវត្តភាព ដែលជាការប្តេជ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងគោលបំណងដើម្បីបង្កើតឱ្យមានបរិយាកាសការងារល្អប្រកបដោយសុខភាព និងសុវត្ថិភាពការងារ សម្រាប់កម្មករនិយោជិតទាំងអស់។ ប្រសិទ្ធភាពនៃ

ផែនការមេនេះ នឹងត្រូវពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំដើម្បីស្វែងរកមធ្យោបាយឱ្យកាន់តែប្រសើរឡើងបន្ថែមទៀតក្នុងការអនុវត្តប្រកបដោយជោគជ័យនូវគោលបំណងអាទិភាពចំនួន៦ចំណុច រួមមាន៖

- គោលបំណងទី១៖ ពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារជាតិ
- គោលបំណងទី២៖ ពង្រឹងការងារអធិការកិច្ច និងការអនុវត្តបទដ្ឋានសុខភាព និងសុវត្ថិភាពការងារ
- គោលបំណងទី៣៖ ជំរុញអង្គការនិយោជក និងអង្គការកម្មករនិយោជិតចូលរួមសកម្មភាពសុខភាព និងសុវត្ថិភាពការងារ
- គោលបំណងទី៤៖ រៀបចំ និងអនុវត្តកម្មវិធីពិសេសសម្រាប់មុខរបរគ្រោះថ្នាក់
- គោលបំណងទី៥៖ ជំរុញឱ្យមានការការពារផ្នែកសុខភាព និងសុវត្ថិភាពការងារ ដល់សហគ្រាសខ្នាតតូច និងមធ្យម និងកន្លែងធ្វើការនៅតាមជនបទ និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- គោលបំណងទី៦៖ គាំទ្រ និងជំរុញកិច្ចសហការផ្នែកសុខភាព និងសុវត្ថិភាពការងារលើ ការងារកុមារ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជំងឺឆ្លង និងជំងឺមិនឆ្លងនៅតាមសហគ្រាស គ្រឹះស្ថាន

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ អង្គការអន្តរជាតិខាងការងារ (ILO) តាមរយៈគម្រោងលើកកម្ពស់ស្តង់ដារសុខភាព និងសុវត្ថិភាពការងារ (ILO/Japan Programme) ដែលបានជួយផ្នែកបច្ចេកទេស និងថវិកា អង្គការនិយោជក អង្គការកម្មករនិយោជិត និងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងអ្នកពាក់ព័ន្ធដទៃទៀតដែលបានរួមចំណែកផ្តល់មតិយោបល់របហូតធ្វើឱ្យផែនការមេលើកទី២ ស្តីពីសុខភាព និងសុវត្ថិភាពការងារឆ្នាំ ២០១៨ - ២០២២ ចេញជារូបរាងឡើង។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ផែនការមេលើកទី២នេះ នឹងត្រូវបានយកទៅប្រើប្រាស់យ៉ាងទូលំទូលាយ និងបង្កភាពងាយស្រួលដល់ភាគីពាក់ព័ន្ធ គ្រប់លំដាប់ថ្នាក់សម្រាប់យកទៅកសាងផែនការសកម្មភាពលម្អិតក្នុងការលើកកម្ពស់ និងកែលំអប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីធានាថាកន្លែងធ្វើការនឹងរក្សាបាននូវបរិយាកាសការងារល្អដែលមានសុខភាព និងសុវត្ថិភាព និងកំណើនផលិតភាពឈានទៅកសាងវប្បធម៌សុខភាព និងសុវត្ថិភាពការងារនៅកន្លែងធ្វើការនាពេលអនាគត។

ថ្ងៃ ពុធ ១កើត ខែបឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៨

រដ្ឋមន្ត្រី

អ៊ិត សំហេង

## មាតិកា


**អារម្ភកថា** ---------- I

**មាតិកា** ---------- II

**សេចក្តីផ្តើម** ---------- ១

**ទស្សនវិស័យ** ---------- ៦

**បេសកកម្ម** ---------- ៦

**គោលបំណងទី១៖ ពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារជាតិ** ---------- ៧

១.១- បន្តស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្តសំខាន់ៗដែលពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពការងារ ---------- ៧

១.២- អនុវត្តគោលនយោបាយជាតិ ស្តីពីសុខភាព និងសុវត្ថិភាពការងារ ---------- ៨

១.៣- ពង្រឹងប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារនៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្តនិងនៅតាមសហគ្រាស គ្រឹះស្ថាន ---------- ៨

១.៤- ពង្រឹងយន្តការពិគ្រោះយោបល់ត្រីភាគីនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅតាមសហគ្រាស គ្រឹះស្ថាន ---------- ៩

១.៥- ពង្រឹងការប្រើប្រាស់បទដ្ឋានពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពការងាររបស់អង្គការអន្តរជាតិខាងការងារជាគោល ---------- ៩

១.៦- លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរក្រសួង អន្តរទីភ្នាក់ងារ និងអន្តរជាតិក្នុងការធ្វើឱ្យប្រសើរឡើងលើវិស័យសុខភាព និងសុវត្ថិភាពការងារនៅកម្ពុជា ---------- ១១

**គោលបំណងទី២៖ ពង្រឹងការងារអធិការកិច្ច និងការអនុវត្តបទដ្ឋានសុខភាព និងសុវត្ថិភាពការងារ** ---------- ១២

២.១- ជំរុញបង្កើតឱ្យមានផែនការយុទ្ធសាស្ត្រ និងអនុវត្តការធ្វើអធិការកិច្ចក្នុងផ្នែកសុខភាព និងសុវត្ថិភាពការងារ ---------- ១២

២.២- បង្កើនសមត្ថភាព ផ្តល់នីតិសម្បទា និងមធ្យោបាយសម្រាប់ការងារអធិការកិច្ច ផ្នែកសុខភាព និងសុវត្ថិភាពការងារ ---------- ១២

២.៣- ពង្រីកដែនសមត្ថកិច្ចការងារអធិការកិច្ចផ្នែកសុខភាព និងសុវត្ថិភាពការងារ ---------- ១៣

២.៤- ពង្រឹងប្រព័ន្ធប្រមូលព័ត៌មានបានិភ័យការងារ ជំងឺវិជ្ជាជីវៈ និងការអង្កេតគ្រោះថ្នាក់ការងារ ---------- ១៤

**គោលបំណងទី៣៖ ជំរុញអង្គការនិយោជក និងអង្គការកម្មករនិយោជិតចូលរួមសកម្មភាពសុខភាព និងសុវត្ថិភាពការងារ** ------ ១៥

៣.១- ជំរុញនិយោជកឱ្យបំពេញបាននូវលក្ខខណ្ឌសុខភាព និងសុវត្ថិភាពការងារក្នុងការធ្វើអាជីវកម្ម---------------------------------------------- ១៥

៣.២- ជំរុញឱ្យសហជីពមូលដ្ឋានមានសកម្មភាពការពារផ្នែកសុខភាព និងសុវត្ថិភាពការងារ ---------------------------------------------------------------------- ១៦

៣.៣- ជំរុញឱ្យមានកិច្ចសហប្រតិបត្តិការរវាងនិយោជក និងកម្មករនិយោជិត ស្តីពីសុខភាព និងសុវត្ថិភាពការងារ ------------------------------------ ១៧

**គោលបំណងទី៤៖ រៀបចំ និងអនុវត្តកម្មវិធីពិសេសសម្រាប់មុខរបរគ្រោះថ្នាក់** ------------------------------------------------------------------- ១៨

៤.១- ពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានសុខភាព និងសុវត្ថិភាពការងារ និងការបណ្តុះបណ្តាលក្នុងវិស័យសំណង់ អាជីវកម្មរ៉ែ គ្រឿងម៉ាស៊ីន និងសេវាកម្មប្លាន្ត------------------------------------------------------------------------------------------------------------- ១៨

៤.២- កែលំអលក្ខខណ្ឌសុខភាព និងសុវត្ថិភាពការងារ សម្រាប់អាជីវកម្មរ៉ែ ------------------------------------------------------------------------------------- ១៩

៤.៣- កំណត់មុខរបរដែលមានហានិភ័យខ្ពស់និងផ្តល់វិធានការការពារពិសេស------------------------------------------------------------------------------------- ២០

**គោលបំណងទី៥៖ ជំរុញឱ្យមានការការពារផ្នែកសុខភាព និងសុវត្ថិភាពការងារ ដល់សហគ្រាសខ្នាតតូច និងមធ្យម និងកន្លែងធ្វើការនៅតាមជនបទ និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ** ------------------------------------------------------------------------- ២១

៥.១- ពង្រីកកម្មវិធី បណ្តុះបណ្តាល ស្តីពីការកែលំអរបៀបធ្វើការងារនៅតាមសហគ្រាសខ្នាតតូច និងមធ្យម----------------------------------------- ២១

៥.២- ពង្រីកកម្មវិធីបណ្តុះបណ្តាល ស្តីពីការកែលំអរបៀបធ្វើការងារដើម្បីសុវត្ថិភាពអ្នកប្រកបការងារនៅតាមផ្ទះ(WISH) ---------------------- ២២

៥.៣- ពង្រីកកម្មវិធីបណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពការងារសម្រាប់កសិករ និងកម្មករនិយោជិតនៅតាមកសិដ្ឋាននានា(WIND)-- ២២

៥.៤- ជំរុញឱ្យមានការបណ្តុះបណ្តាលស្តីពីការកែលំអការងារ និងអភិវឌ្ឍភូមិដ្ឋានសម្រាប់យុវជន (WINDY) ------------------------------------- ២៤

៥.៥- បន្តចងក្រង និងពង្រីកបណ្តាញជនបង្គោល និងអ្នកអនុវត្តកម្មវិធី ស្តីពី WISCON WIND WINDY WISHនិង SMEs ----------------- ២៥

**គោលបំណងទី ៦៖ គាំទ្រ និងជំរុញកិច្ចសហការផ្នែកសុខភាព និងសុវត្ថិភាពការងារលើការងារកុមារ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជំងឺឆ្លង និងជំងឺមិនឆ្លងនៅតាមសហគ្រាស គ្រឹះស្ថាន** ----------------------------------------------------------------២៦

៦.១- ចូលរួមសហការផ្នែកសុខភាព និងសុវត្ថិភាពការងារលើការងារកុមារ--------------------------------------------------------------------------------២៦

៦.២- បន្តជំរុញការអនុវត្តប្រកាស លេខ០៨៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍នៅតាមកន្លែងធ្វើការ និងគោលនយោបាយពាក់ព័ន្ធផ្សេងៗ---------------------------------------------------- ២៧

៦.៣- ធ្វើកិច្ចសហប្រតិបត្តិការអនុវត្តគម្រោង ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជំងឺឆ្លង និង ជំងឺមិនឆ្លងនៅកន្លែងធ្វើការ----------------------២៨

**ទីប្រឹក្សា និងក្រុមការងាររៀបចំផែនការមេ**------------------------------------------------------------------------------------------------------------------២៩

# សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជាបន្តរក្សាបានសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិដោយបានរក្សានូវកំណើន ៧%ក្នុងមួយឆ្នាំជាមួយអត្រាមានការងារធ្វើ ៩៩,៣% ធ្វើឱ្យកម្ពុជាបានប្តូរពីប្រទេសក្រីក្រមកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ហើយកំពុងអភិវឌ្ឍឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលបាននឹងកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើគ្រប់ វិស័យ ជាពិសេសការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សំដៅធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ បង្កើនឱកាសការងារ បង្កើនបរិយាកាសការងារ ពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ និងពង្រឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឱ្យសមស្របតាមតម្រូវការទីផ្សារការងារក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ លើកស្ទួយជីវភាពប្រជាពលរដ្ឋ និងអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពដោយផ្តោតលើកំណែទម្រង់ស៊ីជម្រៅគ្រប់វិស័យ ដូចដែលបានរំលេចឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៥នៃនីតិកាលរដ្ឋសភា ជាពិសេសនៅក្នុងមុំនៃចតុកោណទី៣ ស្តីពីការអភិវឌ្ឍវិស័យឯកជន និងការងារ និងនៅក្នុងមុំចតុកោណទី៤ ស្តីពីការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។

ទន្ទឹមនឹងនោះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានដាក់ចេញនូវកំណែទម្រង់ស៊ីជម្រៅចំនួន៥យុទ្ធសាស្ត្រអាទិភាពរួមមាន៖ (១) ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ (២) ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (៣) ការអភិវឌ្ឍមុខរបរ និងការងារ (៤) ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និង (៥) ការពង្រឹងអភិបាលកិច្ចល្អ។

ដើម្បីចូលរួមសម្រេចនូវគោលដៅយុទ្ធសាស្ត្រខាងលើនេះ ជាពិសេសយុទ្ធសាស្ត្រអាទិភាពទី១ ស្តីពីការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ កម្មវិធីទី៤ ពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមជាមួយស្ថាប័នត្រីភាគី និងដៃគូអភិវឌ្ឍន៍នានា បានដាក់ចេញនូវផែនការមេលើកទី១ ស្តីពីសុខភាព និងសុវត្ថិភាពការងារឆ្នាំ២០០៩-២០១៣ និងបានខិតខំប្រឹងប្រែងអនុវត្តយ៉ាងសកម្មក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដោយទទួលបានលទ្ធផលគួរជាទីមោទនរួមមាន៖

(១) ការពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារថ្នាក់ជាតិៈ

- បានពង្រីកការផ្សព្វផ្សាយ និងជំរុញការអនុវត្តប្រកាសទាក់ទងនឹងសុខភាព និងសុវត្ថិភាពការងារចំនួន ២៥ ក្នុងវិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង វិស័យសំណង់ វិស័យសេវាកម្សាន្ត និងវិស័យដែលស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជាការងារចំការ ស្រែអំបិល និងឡឥដ្ឋជាដើម។

- បានបង្កើនការផ្សព្វផ្សាយស្តីពីសុខភាព និងសុវត្ថិភាពការងារតាមរយៈការរៀបចំទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ ២៨ មេសា ជារៀងរាល់ឆ្នាំ ដោយមានការចូលរួមពីមន្ត្រីជាន់ខ្ពស់ សមាគមនិយោជក កម្មករនិយោជិត សហជីព និងអង្គការដៃគូអភិវឌ្ឍនានា ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីសុខភាព និងសុវត្ថិភាពការងារ។

- បានរៀបចំ និងចូលរួមក្នុងយន្តការត្រីភាគី អន្តរក្រសួង និងអន្តរទីភ្នាក់ងារមានដូចជាៈ ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ គណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីដួលសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិតតាមបណ្តាសហគ្រាស គ្រឹះស្ថាន ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យ និងបញ្ជាក់សុវត្ថិភាពសំណង់រោងចក្រផ្នែកវាយនភណ្ឌកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង និងគណៈកម្មការត្រីភាគីប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ និងគ្រឿងញៀន។

- បានបង្កើតគណៈកម្មការពិគ្រោះយោបល់គម្រោងស្តីពីសុខភាព និងសុវត្ថិភាពការងារ (PAC) និងគណៈកម្មការបច្ចេកទេសចំនួន៣ (PTCs) និងបានរៀបចំប្រព័ន្ធគ្រប់គ្រងរបាយការណ៍ស្តីពីសុខភាព និងសុវត្ថិភាពការងារចាប់ពីថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងនៅតាមសហគ្រាស គ្រឹះស្ថាន។

- បានបន្តកិច្ចព្រមព្រៀងសហប្រតិបត្តិការបច្ចេកទេសជាមួយទីភ្នាក់ងារសុខភាព និងសុវត្ថិភាពការងារកូរ៉េ (KOSHA) ដើម្បីកសាងសមត្ថភាពមន្ត្រីទទួលបន្ទុកអធិការពេទ្យការងារ និងថ្នាក់ដឹកនាំមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត និងការផ្លាស់ប្តូរព័ត៌មានស្តីពីសុខភាព និងសុវត្ថិភាពការងារ។

- បានចែករំលែកបទពិសោធន៍ស្តីពីសុខភាព និងសុវត្ថិភាពការងារនៅក្នុងសហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងក្របខណ្ឌអាស៊ាន តាមរយៈការចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនៃគណៈកម្មការសម្របសម្រួលបណ្តាញសុខភាព និងសុវត្ថិភាពការងារអាស៊ាន (ASEAN-OSHNET Coordinating Board Meeting) សន្និសីទថ្នាក់តំបន់ និងពិភពលោក។

(២) ការកែលម្អការធ្វើអធិការកិច្ចស្តីពីសុខភាព និងសុវត្ថិភាពការងារ និងការអនុវត្តច្បាប់ស្តីពីការងារៈ

- បានធ្វើបច្ចុប្បន្នភាពរបាយការណ៍អធិការពេទ្យការងារដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់។

- បានបង្កើនសមត្ថភាពមន្ត្រីអធិការពេទ្យការងារលើការងារត្រួតពិនិត្យលក្ខខណ្ឌអនាម័យនិងសុវត្ថិភាពការងារ និងបានធ្វើទំនើបកម្មសម្ភារ និងឧបករណ៍អធិការកិច្ចដើម្បីធានាបាននូវគុណភាពអធិការកិច្ច។

(៣) ការជំរុញសកម្មភាពស្តីពីសុខភាព និងសុវត្ថិភាពការងារ តាមរយៈអង្គការនិយោជក និងអង្គការកម្មករនិយោជិត៖

- បានផ្តល់ចំណេះដឹងលើមូលដ្ឋានគ្រឹះផ្នែកសុខភាព និងសុវត្ថិភាពការងារ ការកំណត់ហានិភ័យការងារ និងការគ្រប់គ្រងសារធាតុគីមីដល់អង្គការសហជីព សមាគមនិយោជក និងអ្នកពាក់ព័ន្ធ សំដៅរៀបចំប្រព័ន្ធគ្រប់គ្រងសុខភាពនិងសុវត្ថិភាពការងារនៅកន្លែងធ្វើការឱ្យមានប្រសិទ្ធភាពខ្ពស់ និងកាត់បន្ថយគ្រោះថ្នាក់ការងារ ព្រមទាំងអប់រំផ្សព្វផ្សាយបន្តដល់កម្មករនិយោជិត។

(៤) ការអនុវត្តកម្មវិធីពិសេសសម្រាប់មុខរបរគ្រោះថ្នាក់៖

- បានរៀបចំឱ្យមានគ្រូបង្គោលទាក់ទងនឹងរបៀបធ្វើការនៅតាមការដ្ឋានសំណង់ខ្នាតតូច (WISCON) សម្រាប់បណ្តុះបណ្តាលបន្ត និងបានចុះអង្កេតសិក្សាស្រាវជ្រាវ និងប្រមូលសំណាកលើសម្ភារដែលសង្ស័យមានផ្ទុកសារធាតុអាសបេស្តុស ដូចជាសម្ភារសំណង់ ហ្វ្រាំងឡាន រ៉ៃដែក និងរោងចក្រផលិតស៊ីម៉ងត៍ ថ្មភ្នំ ចម្លាក់ និងថ្នាំលាបផ្ទះនៅតាមរាជធានី ខេត្តមួយចំនួន ដើម្បីកំណត់សម្ភារដែលមានផ្ទុកសារធាតុអាសបេស្តុស និងការចងក្រងព័ត៌មានជាតិស្តីពីសារធាតុអាសបេស្តុសនៅក្នុងប្រទេសកម្ពុជា ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការសុខភាពពិភពលោក (WHO) និងទីភ្នាក់ងារសុខភាព និងសុវត្ថិភាពការងារកូរ៉េ (KOSHA)។

(៥) ការពង្រឹងការការពារផ្នែកសុខភាព និងសុវត្ថិភាពការងារទៅដល់សហគ្រាសខ្នាតតូច និងមធ្យម និងកន្លែងធ្វើការនៅតាមជនបទ និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ៖

- បានអនុវត្តកម្មវិធីការកែលម្អការងារនៅសហគ្រាសខ្នាតតូច (WISE) ការកែលម្អរបៀបធ្វើការងារ ដើម្បីសុវត្ថិភាពអ្នកប្រកបការងារនៅតាមផ្ទះ (WISH) ដល់មន្ត្រីរាជធានីខេត្តតាមរយៈការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោល និងសិក្ខាកាម ដោយសហការជាមួយអង្គការអន្តរជាតិខាងការងារ ដើម្បីកែលម្អលក្ខខណ្ឌការងារដល់អ្នកធ្វើការដែលបាននឹងកំពុងធ្វើការនៅក្នុងវិស័យទាំងនោះ។

(៦) ការជំរុញការអនុវត្តច្បាប់ និងសកម្មភាពរួមសហការជាមួយគម្រោងលុបបំបាត់ពលកម្មកុមារ និងគម្រោងបង្ការការចម្លងមេរោគអេដស៍ និងជំងឺអេដស៍៖

- បានចូលរួមលើកកម្ពស់សកម្មភាពលុបបំបាត់ពលកម្មកុមារនៅកន្លែងធ្វើការ ការចុះអង្កេតលើលក្ខខណ្ឌអនាម័យ និងសុវត្ថិភាពការងារនៅក្នុងសហគ្រាសឡឥដ្ឋ និងបានជំរុញការអនុវត្តប្រកាសលេខ០៨៦ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន ការផ្តល់ប័ណ្ណសរសើរដល់សហគ្រាស គ្រឹះស្ថានដែលអនុវត្តល្អលើការងារបង្ការ និងទប់ស្កាត់ការចម្លងមេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការ និងការជំរុញការអនុវត្តប្រកាសលេខ ១៩៤ ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារនៅតាមសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត តាមរយៈអធិការកិច្ចការងារ និងការបំផុសការផ្សព្វផ្សាយដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត។

- ទោះបីការអនុវត្តផែនការមេលើកទី១ សម្រេចបាននូវលទ្ធផលគួរឱ្យកត់សំគាល់ក្តី ពិនិត្យជារួមនៅមានបញ្ហាប្រឈមដែលតម្រូវឱ្យគ្រប់ភាគីពាក់ព័ន្ធដោះស្រាយឱ្យបានទាន់ពេលវេលា និងស្របតាមសេចក្តីត្រូវការនាពេលបច្ចុប្បន្ន។ បញ្ហាប្រឈមមានដូចជា៖ កង្វះខាតធនធានមនុស្សទាំងនៅថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្តទៅលើចំណេះដឹង ជំនាញ សមត្ថភាពផ្នែកសុខភាព និងសុវត្ថិភាពការងារក្នុងការបំពេញការងារ ការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តនៅមិនទាន់បានទូលំទូលាយ។ ការចូលរួម និងគាំទ្រ តាមរយៈយន្តការសម្របសម្រួលពីភាគីពាក់ព័ន្ធទាំងអស់ក្នុងការពង្រឹងសុខភាព និងសុវត្ថិភាពការងារមិនទាន់បានស៊ីសង្វាក់គ្នានៅឡើយ។ ភាពខ្វះចន្លោះនៃលិខិតបទដ្ឋានគតិយុត្តស្តីពីសុខភាព និងសុវត្ថិភាពការងារដែលប៉ះពាល់ដល់ដំណើរការនៃការអនុវត្តច្បាប់ស្តីពីការងារ និងបទបញ្ញានានាឱ្យមានប្រសិទ្ធភាព។ ការរៀបចំយន្តការការពារសុខភាព និងសុវត្ថិភាពការងារដែលមានលក្ខណៈជាប្រព័ន្ធ គឺជាការងារចាំបាច់ដែលត្រូវការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាននាយកដ្ឋានពេទ្យការងារជាសេនាធិការ បានបន្តដាក់ចេញនូវផែនការមេលើកទី២ ស្តីពីសុខភាពនិងសុវត្ថិភាពការងារ ដែលមានគោលបំណងអាទិភាពចំនួន៦ចំណុច សម្រាប់អនុវត្តរយៈពេល៥ឆ្នាំ (២០១៨ - ២០២២) រួមមាន៖

- គោលបំណងទី១៖ ពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារជាតិ
- គោលបំណងទី២៖ ពង្រឹងការងារអធិការកិច្ច និងការអនុវត្តបទដ្ឋានសុខភាព និងសុវត្ថិភាពការងារ
- គោលបំណងទី៣៖ ជំរុញអង្គការនិយោជក និងអង្គការកម្មករនិយោជិតចូលរួមសកម្មភាពសុខភាព និងសុវត្ថិភាពការងារ
- គោលបំណងទី៤៖ រៀបចំ និងអនុវត្តកម្មវិធីពិសេសសម្រាប់មុខរបរគ្រោះថ្នាក់
- គោលបំណងទី៥៖ ជំរុញឱ្យមានការការពារផ្នែកសុខភាព និងសុវត្ថិភាពការងារ ដល់សហគ្រាសខ្នាតតូច និងមធ្យម និងកន្លែងធ្វើការនៅតាមជនបទ និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- គោលបំណងទី៦៖ គាំទ្រ និងជំរុញកិច្ចសហការផ្នែកសុខភាព និងសុវត្ថិភាពការងារលើ ការងារកុមារ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជំងឺឆ្លង និងជំងឺមិនឆ្លងនៅតាមសហគ្រាស គ្រឹះស្ថាន

ផែនការមេលើកទី២ ស្តីពីសុខភាព និងសុវត្ថិភាពការងារឆ្នាំ២០១៨-២០២២ រៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយតំណាងអង្គការនិយោជក និងអង្គការកម្មករនិយោជិត មន្ត្រីរាជការក្រោមឱវាទនាយកដ្ឋានពេទ្យការងារ នាយកដ្ឋានផ្សេងៗនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថាប័នក្រសួងពាក់ព័ន្ធ ជាពិសេសអង្គការអន្តរជាតិខាងការងារដោយយោងទៅតាមអនុសញ្ញាលេខ១៥៥ស្តីពីសុខភាព និងសុវត្ថិភាពការងារ អនុសញ្ញាលេខ១៨៧ស្តីពី

ក្របខ័ណ្ឌលើកកម្ពស់សុខភាព និងសុវត្ថិភាពការងារ អនុសញ្ញាលេខ១៦៧ ស្តីពីសុខភាព និងសុវត្ថិភាពការងារនៅក្នុងផ្នែកសំណង់ និងអនុសញ្ញាលេខ ៨១ ស្តីពីការធ្វើអធិការកិច្ចការងាររបស់អង្គការអន្តរជាតិខាងការងារ (ILO)។ ផែនការមេនេះ បំពេញតួនាទីជាផែនទីបង្ហាញផ្លូវ និងកាលានុវត្តភាពដែលជាការប្តេជ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងគោលបំណង ដើម្បីបង្កើតឱ្យមានបរិយាកាសការងារល្អប្រកបដោយសុខភាព និងសុវត្ថិភាពការងារសម្រាប់កម្មករនិយោជិតទាំងអស់។ ប្រសិទ្ធភាពនៃផែនការមេនេះ នឹងត្រូវពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំដើម្បីស្វែងរកមធ្យោបាយឱ្យកាន់តែប្រសើរឡើងបន្ថែមទៀតក្នុងការអនុវត្តប្រកបដោយជោគជ័យ។

**ទស្សនវិស័យ៖**

បង្កើត និងលើកកម្ពស់វប្បធម៌ការពារសុខភាព និងសុវត្ថិភាពការងារនៅគ្រប់កន្លែងធ្វើការក្នុងព្រះរាជាណាចក្រកម្ពុជា។

**បេសកកម្ម៖**

- បង្កើត និងអនុវត្តនូវគោលនយោបាយ បទដ្ឋាន និងក្របខ័ណ្ឌច្បាប់ស្ដីពីសុខភាព និងសុវត្ថិភាពការងារដែលគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់អង្គការវិជ្ជាជីវៈក្នុងការជំរុញសកម្មភាពផ្នែកសុខភាព និងសុវត្ថិភាពការងារ
- លើកកម្ពស់សមត្ថភាពមន្ត្រីអធិការការងារ និងអ្នកពាក់ព័ន្ធក្នុងវិស័យសុខភាព និងសុវត្ថិភាពការងារ
- លើកកម្ពស់គុណភាពសេវាសុខភាព និងសុវត្ថិភាពការងារ
- ផ្ដល់ការការពារ និងលើកកម្ពស់ការយល់ដឹងផ្នែកសុខភាព និងសុវត្ថិភាពការងារឱ្យបានទូលំទូលាយដល់និយោជក និងកម្មករនិយោជិតទាំងអស់
- ជំរុញឱ្យមានប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារនៅគ្រប់កន្លែងធ្វើការ។

# ផែនការមេលើកទី២ ស្តីពីសុខភាព និងសុវត្ថិភាពការងារ ឆ្នាំ២០១៨-២០២២

## គោលបំណងទី១៖ ពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារជាតិ

| សកម្មភាព | សភាពការណ៍ | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ១.១-បន្តស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្តសំខាន់ៗដែលពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពការងារ | - ក្របខ័ណ្ឌច្បាប់ ស្តីពីសុខភាព និងសុវត្ថិភាពការងារនៅមិនទាន់ឆ្លើយតបទៅនឹងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន<br>- ការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ស្តីពីសុខភាព និងសុវត្ថិភាពការងារមិនទាន់បានទូលំទូលាយទៅដល់សហគ្រាស គ្រឹះស្ថាន<br>- ការចូលរួមពីអង្គការនិយោជក និងអង្គការកម្មករនិយោជិតនៅមានកម្រិត។ | - ស្រាវជ្រាវ និងរៀបចំបង្កើតច្បាប់ស្តីពីសុខភាព និងសុវត្ថិភាពការងារ<br>- បន្តរៀបចំកែសម្រួលលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដើម្បីឱ្យសមស្របទៅតាមស្ថានភាពសេដ្ឋកិច្ច<br>- បន្តរៀបចំសេចក្តីព្រាងប្រកាស និងលិខិតបទដ្ឋានបន្ថែមទៀតពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពការងារនៅគ្រប់វិស័យជាពិសេស វិស័យសំណង់ រ៉ែ សេវាកម្មភ្លូន សារធាតុគីមី និងសុវត្ថិភាពគ្រឿងម៉ាស៊ីន<br>- ស្វែងរកការគាំទ្រផ្នែកបច្ចេកទេសផ្នែកច្បាប់ និងសុខភាពសុវត្ថិភាពការងារពីអ្នកជំនាញជាតិ និងអន្តរជាតិ<br>- រៀបចំគម្រោងថវិកាជាតិ និងគៀងគរហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូនានាសម្រាប់រៀបចំបទដ្ឋានគតិយុត្ត និងការផ្សព្វផ្សាយ។ | - ច្បាប់ស្តីពីសុខភាព និងសុវត្ថិភាពការងារត្រូវបានរៀបចំ និងអនុវត្ត<br>- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងត្រូវបានរៀបចំកែសម្រួលឱ្យសមស្របតាមស្ថានភាពសេដ្ឋកិច្ច<br>- ប្រកាសថ្មីៗ និងលិខិតបទដ្ឋានគតិយុត្តស្តីពីសុខភាព និងសុវត្ថិភាពការងារនឹងត្រូវបានអនុម័ត និងផ្សព្វផ្សាយ។ |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ១.២-អនុវត្តគោលនយោបាយជាតិ ស្តីពីសុខភាព និងសុវត្ថិភាពការងារ | - គោលនយោបាយជាតិ ស្តីពីសុខភាព និងសុវត្ថិភាពការងារនឹងត្រូវរៀបចំ និងពិនិត្យដោយគណៈកម្មាធិការជាតិ ស្តីពីសុខភាព និងសុវត្ថិភាពការងារ | - ផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពីសុខភាព និងសុវត្ថិភាពការងារដល់គ្រប់ភាគីពាក់ព័ន្ធ<br>- ជំរុញការអនុវត្តគោលនយោបាយជាតិ ស្តីពីសុខភាព និងសុវត្ថិភាពការងារនៅតាមសហគ្រាស គ្រឹះស្ថាន។ | - គោលនយោបាយជាតិ ស្តីពីសុខភាព និងសុវត្ថិភាពការងារ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល ត្រូវបានផ្សព្វផ្សាយនិងអនុវត្ត។ |
| ១.៣-ពង្រឹងប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារនៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងនៅតាមសហគ្រាស គ្រឹះស្ថាន | - ប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារនៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងនៅតាមសហគ្រាស គ្រឹះស្ថាន នៅមានកម្រិតក្នុងការបំពេញមុខងារដើម្បីវាយតម្លៃហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពការងារ និងកាត់បន្ថយគ្រោះថ្នាក់ឱ្យមានប្រសិទ្ធភាពខ្ពស់ | - បង្កើតឱ្យមានប្រកាស និងគោលការណ៍ណែនាំ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការសុខភាព និងសុវត្ថិភាពការងារនៅតាមសហគ្រាស គ្រឹះស្ថាន<br>- រៀបចំកម្មវិធីបណ្តុះបណ្តាល និងផ្សព្វផ្សាយស្តីពីប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅតាមសហគ្រាស គ្រឹះស្ថាន<br>- ជំរុញម្ចាស់សហគ្រាស គ្រឹះស្ថានឱ្យរៀបចំប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ និងមន្ត្រីសុវត្ថិភាពការងារនៅកន្លែងធ្វើការ | - ប្រកាស និងគោលការណ៍ណែនាំ ស្តីពីសុខភាព និងសុវត្ថិភាពការងារនឹងត្រូវបានដាក់ឱ្យអនុវត្ត<br>- គណៈកម្មការសុខភាព និងសុវត្ថិភាពការងារនៅថ្នាក់សហគ្រាសត្រូវបានអនុវត្ត<br>- ប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារនៅតាមសហគ្រាស គ្រឹះស្ថាន ត្រូវបានបណ្តុះបណ្តាលនិងផ្សព្វផ្សាយនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅតាមសហគ្រាស គ្រឹះស្ថាន |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| | | - រៀបចំកិច្ចប្រជុំរវាងមន្ត្រីការងារនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ឬថ្នាក់សហគ្រាស គ្រឹះស្ថានជាទៀងទាត់។ | - កិច្ចប្រជុំថ្នាក់ជាតិ ត្រូវរៀបចំជាទៀងទាត់ ដើម្បីតាមដានការអនុវត្ត។ |
| ១.៤-ពង្រឹងយន្តការពិគ្រោះយោបល់ត្រីភាគីនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅតាមសហគ្រាស គ្រឹះស្ថាន | - គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារទើបនឹងបង្កើត<br>- យន្តការពិគ្រោះយោបល់ត្រីភាគី ស្តីពីសុខភាព និងសុវត្ថិភាពការងារថ្នាក់រាជធានី ខេត្ត និងនៅតាមសហគ្រាស គ្រឹះស្ថាននៅមានកម្រិត។ | - ជំរុញការអនុវត្តអនុក្រឹត្យ ស្តីពីគណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ<br>- បន្តកិច្ចប្រជុំពិគ្រោះយោបល់ត្រីភាគីជាទៀងទាត់ក្នុងការផ្តល់យោបល់ដល់រាជរដ្ឋាភិបាល ដើម្បីបង្កើតគោលនយោបាយ និងកម្មវិធីស្តីពីសុខភាព និងសុវត្ថិភាពការងារ។ | - យន្តការត្រីភាគីនឹងត្រូវបានអនុវត្តឱ្យមានប្រសិទ្ធភាព និងបំពេញមុខងារបានត្រឹមត្រូវ។ |
| ១.៥- ពង្រឹងការប្រើប្រាស់បទដ្ឋានពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពការងាររបស់អង្គការអន្តរជាតិខាងការងារជាគោល | - ប្រទេសកម្ពុជាពុំទាន់បានបង្កើតនូវបទដ្ឋានបច្ចេកទេសស្តីពីសុខភាព និងសុវត្ថិភាពការងារ<br>- ការរៀបចំតាក់តែងលិខិតគតិយុត្តស្តីពីសុខភាព និងសុវត្ថិភាពការងារ ដោយប្រើប្រាស់បទដ្ឋានពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពការងាររបស់អង្គការអន្តរជាតិខាងការងារជាគោល។ | - បន្តប្រើប្រាស់លិខិតគតិយុត្តស្តីពីសុខភាព និងសុវត្ថិភាពការងាររបស់អង្គការអន្តរជាតិខាងការងារ ដើម្បីលើកកម្ពស់ក្របខណ្ឌច្បាប់ស្តីពីសុខភាព និងសុវត្ថិភាពការងារ | - លិខិតគតិយុត្តសំខាន់ៗស្តីពីសុខភាព និងសុវត្ថិភាពការងារដែលមានប្រយោជន៍សម្រាប់សេចក្តីត្រូវការបន្ទាន់ផ្នែកសុខភាព និងសុវត្ថិភាពការងារក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រើប្រាស់ រួមមាន<br>- អនុសញ្ញាលេខ៨១ ស្តីពីការធ្វើអធិការកិច្ចការងារ<br>- អនុសញ្ញាលេខ១១០ ស្តីពីលក្ខខណ្ឌការងារនៅតាមចំការ |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
| --- | --- | --- | --- |
| | | | - អនុសញ្ញាលេខ១៥៥ ស្តីពីសុខភាព និងសុវត្ថិភាពការងារ<br>- អនុសញ្ញាលេខ ១៦៧ ស្តីពីសុខភាព និងសុវត្ថិភាពក្នុងវិស័យសំណង់<br>- អនុសញ្ញាលេខ ១៨៤ ស្តីពីសុខភាព និងសុវត្ថិភាពក្នុងវិស័យកសិកម្ម<br>- អនុសញ្ញាលេខ ១៨៧ ស្តីពីក្របខណ្ឌផ្សព្វផ្សាយ អំពីសុខភាព និងសុវត្ថិភាពការងារ ឬគោលការណ៍ណែនាំរបស់អង្គការអន្តរជាតិខាងការងារស្តីពីប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ។ |

| សកម្មភាព | សមិទ្ធផល | យុទ្ធសាស្ត្រ | ចំណុចខ្សោយ |
|---|---|---|---|
| ១.៦-លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរក្រសួងអន្តរទីភ្នាក់ងារ និងអន្តរជាតិ ក្នុងការធ្វើឱ្យប្រសើរឡើងលើវិស័យសុខភាព និងសុវត្ថិភាពការងារនៅកម្ពុជា | - ការអភិវឌ្ឍវិស័យសុខភាព និងសុវត្ថិភាពការងារត្រូវការផ្លាស់ប្តូរបទពិសោធន៍រវាងប្រទេសកម្ពុជា នៅក្នុងតំបន់ និងអន្តរជាតិ<br>- កិច្ចសហប្រតិបត្តិការអន្តរក្រសួងអន្តរទីភ្នាក់ងារ និងអន្តរជាតិផ្នែកសុខភាព និងសុវត្ថិភាពការងារនៅមិនទាន់បានទូលំទូលាយ | - បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការ ឬទីភ្នាក់ងារដៃគូជាតិ និងអន្តរជាតិដូចជាអង្គការអន្តរជាតិខាងការងារ(ILO) អង្គការសុខភាពពិភពលោក (WHO) បណ្តាញសុខភាព និងសុវត្ថិភាពការងារអាស៊ាន (ASEAN-OSHNET)<br>- វិទ្យាស្ថានជាតិសុខភាព និងសុវត្ថិភាពការងារម៉ាឡេស៊ី (NIOSH) ទីភ្នាក់ងារសុខភាព និងសុវត្ថិភាពការងារកូរ៉េ (KOSHA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) សមាគមសុខភាព និងសុវត្ថិភាពការងារឧស្សាហកម្មជប៉ុន (JISHA) និងជាមួយបណ្តាប្រទេសអាស៊ាន និងដៃគូអភិវឌ្ឍនានា។ | - មានការផ្លាស់ប្តូរបទពិសោធន៍ផ្នែកសុខភាព និងសុវត្ថិភាពការងារនៅក្នុងតំបន់ និងអន្តរជាតិ។<br>- សមត្ថភាពមន្ត្រីសុខភាព និងសុវត្ថិភាពការងារត្រូវបានពង្រឹង។ |

**គោលបំណងទី២៖ ពង្រឹងការងារអធិការកិច្ច និងការអនុវត្តបទដ្ឋានសុខភាព និងសុវត្ថិភាពការងារ**

| សកម្មភាព | សន្និដ្ឋានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ២.១-ជំរុញបង្កើតឱ្យមានផែនការយុទ្ធសាស្ត្រ និងអនុវត្តការធ្វើអធិការកិច្ចក្នុងផ្នែកសុខភាព និងសុវត្ថិភាពការងារ | - មិនទាន់មានផែនការយុទ្ធសាស្ត្រសម្រាប់អធិការកិច្ចការងារលើវិស័យឧស្សាហកម្ម និងកន្លែងធ្វើការដែលមានហានិភ័យខ្ពស់<br>- ការចុះធ្វើអធិការកិច្ចសម្រាប់វិស័យឧស្សាហកម្មដែលមានហានិភ័យខ្ពស់នៅមានកម្រិត<br>- ការចូលរួមពីអង្គការនិយោជក និងអង្គការកម្មករនិយោជិតនៅមានកម្រិត | - កំណត់ប្រភេទឧស្សាហកម្ម និងកន្លែងធ្វើការដែលមានហានិភ័យខ្ពស់ជាអាទិភាពសម្រាប់អធិការកិច្ច<br>- រៀបចំផែនការអធិការកិច្ចប្រចាំឆ្នាំ<br>- វិភាគ និងពិនិត្យឡើងវិញអំពីលទ្ធផលអធិការកិច្ចប្រចាំឆ្នាំ<br>- ធ្វើទំនើបកម្មសម្ភារ និងឧបករណ៍សម្រាប់ចុះធ្វើអធិការកិច្ចផ្នែកសុខភាព និងសុវត្ថិភាពការងារ។ | - វិស័យឧស្សាហកម្ម និងកន្លែងធ្វើការដែលមានហានិភ័យខ្ពស់ជាអាទិភាពសម្រាប់ធ្វើអធិការកិច្ចត្រូវបានកំណត់<br>- ផែនការអធិការកិច្ចត្រូវបានអនុវត្ត<br>- របាយការណ៍ប្រចាំឆ្នាំស្តីពីលទ្ធផលអធិការកិច្ច ត្រូវបានបោះពុម្ពផ្សាយ<br>- សម្ភារ និងឧបករណ៍អធិការកិច្ចត្រូវបានបំពាក់ និងបំពេញតាមតម្រូវការ។ |
| ២.២-បង្កើនសមត្ថភាពផ្តល់នីតិសម្បទា និងមធ្យោបាយសម្រាប់ការងារអធិការកិច្ច ផ្នែកសុខភាព និងសុវត្ថិភាពការងារ | - សមត្ថភាពអធិការកិច្ចស្តីពីសុខភាព និងសុវត្ថិភាពការងារ និងមធ្យោបាយសម្រាប់ការធ្វើអធិការកិច្ចការងារពុំទាន់មានសមត្ថកិច្ចគ្រប់គ្រាន់<br>- មន្ត្រីអធិការកិច្ចការងារពុំទាន់មាននីតិសម្បទាពេញលេញ | - រៀបចំនីតិវិធីក្នុងការស្នើសុំផ្តល់នីតិសម្បទាពេញលេញ(សិទ្ធអំណាច) ដល់មន្ត្រីអធិការកិច្ចការងារ<br>- រៀបចំគោលការណ៍ណែនាំអំពីការងារបច្ចេកទេសអធិការកិច្ច<br>- រៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីអធិការកិច្ច<br>- រៀបចំកិច្ចប្រជុំ ស្តីពីការងារអធិការកិច្ចដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយដៃគូពាក់ព័ន្ធផ្សេងៗ | - អំណាចស្របច្បាប់និងតួនាទីភារកិច្ចរបស់មន្ត្រីអធិការកិច្ច ត្រូវបានកំណត់ច្បាស់លាស់<br>- មន្ត្រីអធិការកិច្ចត្រូវបានបង្កើនសមត្ថភាព ជានាគុណភាពប្រព័ន្ធជ្រើសរើស និងបណ្តុះបណ្តាលត្រូវបានពង្រឹង។ |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| | | - ពង្រឹងការកែលំអប្រព័ន្ធជ្រើសរើសមន្ត្រីអធិការកិច្ច<br>- ផ្ដល់មធ្យោបាយ សម្ភារ និងឧបករណ៍សម្រាប់ចុះធ្វើអធិការកិច្ចផ្នែកសុខភាព និងសុវត្ថិភាពការងារ។ | |
| ២.៣-ពង្រីកដែនសមត្ថកិច្ចការងារអធិការកិច្ចផ្នែកសុខភាព និងសុវត្ថិភាពការងារ | - អធិការកិច្ចការងារបានចុះធ្វើអធិការកិច្ចភាគច្រើនតែលើវិស័យវាយនភ័ណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង តែការធ្វើអធិការកិច្ចការងារនៅតាមវិស័យមួយចំនួនមិនទាន់អនុវត្តដល់ដូចជាការដ្ឋានសំណង់ អាជីវកម្មរ៉ែ សេវាកម្សាន្តជាដើម<br>- មិនទាន់មានការចុះអធិការកិច្ចការងារនៅតាមសហគ្រាសខ្នាតតូច និងកន្លែងធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ | - រៀបចំកម្មវិធីចុះធ្វើអធិការកិច្ចទៅដល់កន្លែងធ្វើការច្រើនទៀត ជាពិសេសទៅដល់ការដ្ឋានសំណង់ អាជីវកម្មរ៉ែ សេវាកម្សាន្ត សហគ្រាសខ្នាតតូច និងមធ្យម និងកន្លែងធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជា កន្លែងអាជីវកម្មនៅតាមផ្ទះ កសិដ្ឋាន ឬសិប្បកម្មឡឥដ្ឋ<br>- ពិនិត្យឡើងវិញអំពីលទ្ធផលសម្រេចបាននាពេលកន្លងមក និងក្បួនអនុវត្តល្អៗ ក្នុងការពង្រីកសេវាទៅដល់កន្លែងធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយប្រើប្រាស់បទពិសោធន៍ទាំងនេះដើម្បីរៀបចំផែនការធ្វើអធិការកិច្ច | - សេវាអធិការកិច្ច ត្រូវបានពង្រីកទៅដល់ការដ្ឋានសំណង់ អាជីវកម្មរ៉ែ សេវាកម្សាន្ត សិប្បកម្មឡឥដ្ឋ សហគ្រាសខ្នាតតូច និងមធ្យម ព្រមទាំងកន្លែងធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងជនបទតាមការជ្រើសរើស<br>- ផែនការសកម្មភាពត្រូវបានរៀបចំឡើងដើម្បីបង្កើនដែនគ្របដណ្ដប់នៃសេវាអធិការកិច្ច។ |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ២.៤-ពង្រឹងប្រព័ន្ធប្រមូលព័ត៌មានហានិភ័យការងារ ជំងឺវិជ្ជាជីវៈ និងការអង្កេតគ្រោះថ្នាក់ការងារ | - ប្រព័ន្ធប្រមូល និងវិភាគព័ត៌មាន និងគ្រប់គ្រងរបាយការណ៍ អំពីហានិភ័យការងារ ជំងឺវិជ្ជាជីវៈ និងការអង្កេតគ្រោះថ្នាក់ការងារ មិនទាន់មានប្រសិទ្ធភាព<br>- ខ្វះកិច្ចសហការពីបណ្តាសហគ្រាស គ្រឹះស្ថាន ក្នុងការផ្តល់ព័ត៌មានស្តីពីគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈមកនាយកដ្ឋានពេទ្យការងារឱ្យបានទាន់ពេលវេលា<br>- មិនទាន់មានប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ | - រៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងរបាយការណ៍ហានិភ័យការងារ ជំងឺវិជ្ជាជីវៈ និងការអង្កេតគ្រោះថ្នាក់ការងារ<br>- បង្កើតគំរូរបាយការណ៍ ស្តីពីការចុះអង្កេតគ្រោះថ្នាក់ការងារ ហានិភ័យការងារ និងជំងឺវិជ្ជាជីវៈ<br>- ផ្សព្វផ្សាយប្រព័ន្ធគ្រប់គ្រងរបាយការណ៍ និងគំរូរបាយការណ៍ ហានិភ័យការងារ ជំងឺវិជ្ជាជីវៈ និងការអង្កេតគ្រោះថ្នាក់ការងារ<br>- ប្រមូល និងវិភាគទិន្នន័យអំពីហានិភ័យការងារជំងឺវិជ្ជាជីវៈ និងការអង្កេតគ្រោះថ្នាក់ការងារ<br>- សហការជាមួយដៃគូពាក់ព័ន្ធ ដើម្បីទទួលបានទិន្នន័យហានិភ័យការងារ ជំងឺវិជ្ជាជីវៈ និងការអង្កេតគ្រោះថ្នាក់ការងារ<br>- ផ្សព្វផ្សាយរបាយការណ៍ហានិភ័យការងារ ជំងឺវិជ្ជាជីវៈ និងការអង្កេតគ្រោះថ្នាក់ការងារ និងមានវិធានការ។ | - ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ និងគំរូរបាយការណ៍ហានិភ័យការងារ ជំងឺវិជ្ជាជីវៈ និងការអង្កេតគ្រោះថ្នាក់ការងារត្រូវបានបង្កើត ផ្សព្វផ្សាយ និងធ្វើបច្ចុប្បន្នភាព<br>- របាយការណ៍គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ ត្រូវបានផ្សព្វផ្សាយ និងផ្តល់វិធានការក្នុងការកាត់បន្ថយគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈនៅកន្លែងធ្វើការ។ |

## គោលបំណងទី៣៖ ជំរុញអង្គការនិយោជក និងអង្គការកម្មករនិយោជិតចូលរួមសកម្មភាពសុខភាព និងសុវត្ថិភាពការងារ

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ៣.១-ជំរុញនិយោជកឱ្យបំពេញបាននូវលក្ខខណ្ឌសុខភាព និងសុវត្ថិភាពការងារក្នុងការធ្វើអាជីវកម្ម | - នៅតាមកន្លែងធ្វើការមួយចំនួននៅប្រទេសកម្ពុជាពុំទាន់បានអនុវត្តត្រឹមត្រូវតាមគោលការណ៍ស្តីពីសុខភាព និងសុវត្ថិភាពការងារ<br>- និយោជកត្រូវផ្សារភ្ជាប់សកម្មភាពនិងគោលការណ៍ណែនាំស្តីពីសុខភាព និងសុវត្ថិភាពការងារឱ្យសមស្រប ដើម្បីបង្កើនការប្រកួតប្រជែងខាងអាជីវកម្មរបស់ខ្លួននៅក្នុងសេដ្ឋកិច្ចសកលភាវូបនីយកម្ម | - ជំរុញ និងលើកទឹកចិត្ត និយោជកឱ្យផ្សារភ្ជាប់សកម្មភាពស្តីពីសុខភាព និងសុវត្ថិភាពការងារទៅនឹងការបង្កើនផលិតភាព និងគោលដៅគ្រប់គ្រងអាជីវកម្ម<br>- ណែនាំនិយោជកឱ្យប្រើប្រាស់លិខិតតូបករណ៍ ស្តីពីសុខភាព និងសុវត្ថិភាពការងារ របស់អង្គការអន្តរជាតិខាងការងារធ្វើជាគោលការណ៍ណែនាំសម្រាប់អាជីវកម្ម<br>- ជំរុញឱ្យនិយោជកបង្កើត និងអនុវត្តគោលនយោបាយស្តីពីសុខភាព និងសុវត្ថិភាពការងារ និងផែនការសកម្មភាពស្តីពី សុខភាព និងសុវត្ថិភាពការងារ<br>- រៀបចំធ្វើសិក្ខាសាលា និងកម្មវិធីបណ្តុះបណ្តាល ស្តីពីសុខភាព និងសុវត្ថិភាពការងារដើម្បីបំពេញតាមតម្រូវការរបស់និយោជក។ | - គ្រប់សហគ្រាសគ្រឹះស្ថានបានអនុវត្តល្អផ្នែកសុខភាព និងសុវត្ថិភាពការងារ<br>- ផែនការសកម្មភាពស្តីពីសុខភាព និងសុវត្ថិភាពការងារ ត្រូវបានរៀបចំ និងអនុវត្តដោយនិយោជក និងអង្គការរបស់ខ្លួន<br>- បង្កើនចំណេះដឹង និងការអនុវត្តជាក់ស្តែងស្តីពីសុខភាព និងសុវត្ថិភាពការងារដល់និយោជក។ |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ៣.២-ជំរុញឱ្យសហជីពមូលដ្ឋានមានសកម្មភាពការពារផ្នែកសុខភាព និងសុវត្ថិភាពការងារ | - សហជីពមានលទ្ធភាពទាក់ទងដោយផ្ទាល់ជាមួយកម្មករនិយោជិតជាច្រើន ហើយក៏អាចពង្រីកសេវាទៅដល់ក្រុមអ្នកធ្វើការទាំងឡាយដែលងាយរងគ្រោះ<br>- សកម្មភាពការពារផ្នែកសុខភាព និងសុវត្ថិភាពការងារដល់កម្មករនិយោជិតពីសំណាក់សហជីពមូលដ្ឋាននៅមានកម្រិត | - បណ្តុះបណ្តាលគ្រូបង្គោលផ្នែកសុខភាព និងសុវត្ថិភាពការងារសម្រាប់សហជីពមូលដ្ឋាន<br>- ជួយគ្រូបង្គោលរបស់សហជីពមូលដ្ឋានក្នុងការរៀបចំសកម្មភាពបណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពការងារដល់កម្មករនិយោជិត<br>- ជំរុញ និងលើកទឹកចិត្តនិយោជក និងផ្តល់ឱកាសឱ្យគ្រូបង្គោលសហជីពមូលដ្ឋានបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។ | - កន្លែងធ្វើការដែលគេពិបាកផ្តល់សេវា និងក្រុមអ្នកធ្វើការដែលងាយរងគ្រោះបានទទួលការបណ្តុះបណ្តាលពីគ្រូបង្គោលផ្នែកសុខភាព និងសុវត្ថិភាពការងាររបស់សហជីពមូលដ្ឋាន<br>- សកម្មភាព និងការបណ្តុះបណ្តាលស្តីពី សុខភាព និងសុវត្ថិការងារត្រូវបានគ្រោងឡើង និងអនុវត្តដោយសហជីពមូលដ្ឋាន<br>- កំណត់តួនាទីនិងភារកិច្ចរបស់សហជីពមូលដ្ឋានក្នុងប្រកាស ស្តីពីគណៈកម្មការសុខភាព និងសុវត្ថិភាពការងារថ្នាក់សហគ្រាស។ |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ៣.៣-ជំរុញឱ្យមានកិច្ចសហប្រតិបត្តិការរវាងនិយោជក និងកម្មករនិយោជិតស្តីពីសុខភាព និងសុវត្ថិភាពការងារ | - កិច្ចសហការរវាងនិយោជក និងកម្មករនិយោជិត ស្តីពីសុខភាព និងសុវត្ថិភាពការងារ នៅកន្លែងធ្វើការនៅមិនទាន់មានប្រសិទ្ធភាព<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវការឱ្យនិយោជក និងកម្មករនិយោជិតធ្វើការរួមគ្នា ដើម្បីឱ្យកន្លែងធ្វើការមានសុវត្ថិភាព និងសុខភាពល្អ | - ជំរុញឱ្យបង្កើតគណៈកម្មការ ស្តីពីសុខភាព និងសុវត្ថិភាពការងារនៅតាមសហគ្រាស គ្រឹះស្ថាន<br>- ជំរុញឱ្យបង្កើតមានគោលនយោបាយស្តីពីសុខភាព និងសុវត្ថិការងារនៅកន្លែងធ្វើការនៃសហគ្រាស គ្រឹះស្ថាន<br>- ជំរុញឱ្យមានសកម្មភាព និងយុទ្ធនាការរួមគ្នាស្តីពី សុខភាព និងសុវត្ថិភាពការងារ។ | - គណៈកម្មការសុខភាព និងសុវត្ថិភាពការងារនៅតាមសហគ្រាស គ្រឹះស្ថានត្រូវបានបង្កើត និងដំណើរការ<br>- គោលនយោបាយស្តីពីសុខភាព និងសុវត្ថិការងារនៅតាមសហគ្រាស គ្រឹះស្ថានត្រូវបានបង្កើត និងអនុវត្ត<br>- និយោជក និងកម្មករនិយោជិត បានរួមចំណែកក្នុងសកម្មភាពកែលម្អសុខភាព និងសុវត្ថិភាពការងារនៅតាមសហគ្រាស គ្រឹះស្ថាន។ |

**គោលបំណងទី៤៖ រៀបចំ និងអនុវត្តកម្មវិធីពិសេសសម្រាប់មុខរបរគ្រោះថ្នាក់**

| សកម្មភាព | សន្និទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ៤.១-ពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានសុខភាព និងសុវត្ថិភាពការងារ និងការបណ្តុះបណ្តាលក្នុងវិស័យសំណង់ អាជីវកម្មរ៉ែ គ្រឿងម៉ាស៊ីន និងសេវាកម្សាន្ត | - ការធ្វើអធិការកិច្ចការងារ ក្នុងវិស័យសំណង់ អាជីវកម្មរ៉ែ គ្រឿងម៉ាស៊ីន និងសេវាកម្សាន្ត ពុំទាន់បានទូលំទូលាយ<br>- ខ្វះបទដ្ឋានសុខភាព និងសុវត្ថិភាពការងារផ្នែកវិស័យសំណង់អាជីវកម្មរ៉ែ គ្រឿងម៉ាស៊ីន និង សេវាកម្សាន្ត<br>- ខ្វះកិច្ចសហការពីនិយោជក ឬតំណាងម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត | - រៀបចំប្រកាសបន្ថែម និងបទដ្ឋានសុខភាព និងសុវត្ថិភាពការងារសម្រាប់វិស័យសំណង់ អាជីវកម្មរ៉ែ គ្រឿងម៉ាស៊ីន និងសេវាកម្សាន្ត<br>- អនុវត្តបទដ្ឋានសុខភាព និងសុវត្ថិភាពការងារក្នុងវិស័យសំណង់ អាជីវកម្មរ៉ែ គ្រឿងម៉ាស៊ីន និងសេវាកម្សាន្ត<br>- ពង្រឹងការធ្វើអធិការកិច្ចការងារនៅក្នុងការដ្ឋានសំណង់ អាជីវកម្មរ៉ែ គ្រឿងម៉ាស៊ីន និងសេវាកម្សាន្ត ដោយចាត់ទុកជាអាទិភាពបន្ទាន់<br>- បន្តការបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចស្តីពីសុវត្ថិភាពការងារក្នុងវិស័យសំណង់ អាជីវកម្មរ៉ែ គ្រឿងម៉ាស៊ីន និងសេវាកម្សាន្ត<br>- បន្តពង្រីកកម្មវិធីបណ្តុះបណ្តាលស្តីពីការកែលម្អរបៀបធ្វើការងារ នៅតាមការដ្ឋានសំណង់ខ្នាតតូច(WISCON) ទៅដល់កម្មករសំណង់ឱ្យបានទូទាំងប្រទេស។ | - ប្រកាសថ្មីស្តីពីសុខភាព និងសុវត្ថិភាពការងារក្នុងវិស័យសំណង់ត្រូវអនុម័ត<br>- ផែនការធ្វើអធិការកិច្ចជាយុទ្ធសាស្ត្រសម្រាប់វិស័យសំណង់ និងសេវាកម្សាន្តត្រូវបានអនុវត្ត<br>- មន្ត្រីអធិការកិច្ចត្រូវបានពង្រឹងសមត្ថភាពបន្ថែមស្តីពីសុខភាព និងសុវត្ថិភាពការងារលើវិស័យសំណង់ និងសេវាកម្សាន្ត<br>- កម្មវិធីការកែលម្អរបៀបធ្វើការនៅតាមការដ្ឋានសំណង់ខ្នាតតូច (WISCON) ត្រូវបានផ្សព្វផ្សាយទៅដល់និយោជក សមាគមសាងសង់ និងភាគីពាក់ព័ន្ធ។ កម្មករនិយោជិតច្រើននាក់បន្ថែមទៀតទទួលបានការបណ្តុះបណ្តាល ស្តីពីការកែលម្អរបៀបធ្វើការងារនៅតាមការដ្ឋានសំណង់ខ្នាតតូច(WISCON)ពីគ្រូបង្គោល |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
| --- | --- | --- | --- |
| | | - ជំរុញការអនុវត្តប្រកាសលេខ ១៩៤ ប្រកាសលេខ ១៧៦ និងប្រកាសលេខ០៧៥ ០៧៦ ០៧៧ និង០៧៨<br>- អនុវត្តជាគោលតាមអនុសញ្ញាលេខ ១៦៧ ស្តីពីសុខភាព និងសុខភាពក្នុងវិស័យសំណង់ អនុសញ្ញាលេខ ១៦២ ស្តីពីសុវត្ថិភាពក្នុងការ ប្រើប្រាស់សារធាតុអាសបេស្តុស និងដំណោះស្រាយ សន្និសីទអន្តរជាតិរបស់អង្គការអន្តរជាតិខាងការងារ (ILO) ស្តីពីការប្រើប្រាស់សារធាតុអាសបេស្តុស ឆ្នាំ២០០៦។ | - ប្រកាសលេខ ១៩៤ ត្រូវបានអនុវត្តតាមសហគ្រាស គ្រឹះស្ថាន និងសេវាកម្មក្នុង ប្រកាសលេខ ១៧៦ ០៧៥ ០៧៦ ០៧៧ និង០៧៨ត្រូវបានអនុវត្តតាមសហគ្រាស និងការដ្ឋានសំណង់។ |
| ៤.២-កែលម្អលក្ខខណ្ឌសុខភាព និងសុវត្ថិភាពការងារសម្រាប់អាជីវកម្មរ៉ែ | - អាជីវកម្មរ៉ែ (ដែក មាស អាលុយមីញ៉ូម និងប្រេង។ល។) បង្កឱ្យមានហានិភ័យនៃគ្រោះថ្នាក់ខ្ពស់។ កម្មករនិយោជិត និងនិយោជកនៅក្នុងអាជីវកម្មរ៉ែ ត្រូវការជាបន្ទាន់នូវកម្មវិធីពិសេស ដើម្បីកែលម្អ លក្ខខណ្ឌសុខភាព និងសុវត្ថិភាពការងារ។ | - កំណត់កន្លែងជីករ៉ែដែលមានហានិភ័យខ្ពស់ និងប៉ាន់ប្រមាណអំពីហានិភ័យផ្នែកសុខភាព និងសុវត្ថិភាព ដោយរៀបចំកម្មវិធីកែលម្អ<br>- បណ្តុះបណ្តាលកម្មករនិយោជិត និងនិយោជកក្នុងអាជីវកម្មរ៉ែ អំពីវិធានការកែលម្អជាក់ស្តែងស្តីពីសុខភាព និងសុវត្ថិភាពការងារ។ | - បញ្ជីអាជីវកម្មរ៉ែត្រូវបានរៀបចំឡើង<br>- កម្មករនិយោជិត និងនិយោជកក្នុងអាជីវកម្មរ៉ែបានទទួលការបណ្តុះបណ្តាលអំពីវិធានការកែលម្អជាក់ស្តែងស្តីពីសុខភាព និងសុវត្ថិភាពការងារ។ |

| សកម្មភាព | សន្និធានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| | | - រៀបចំគោលការណ៍ណែនាំស្តីពីលក្ខខណ្ឌ សុខភាព និងសុវត្ថិភាពការងារ សម្រាប់អាជីវកម្មរ៉ែ ដោយប្រើអនុសញ្ញាលេខ១៧៦ ស្តីពីសុខភាព និងសុវត្ថិភាពក្នុងវិស័យរ៉ែ របស់អង្គការអន្តរជាតិខាងការងារ(ILO) សម្រាប់ជាគោល។ | - គោលការណ៍ណែនាំ និងសម្ភារផ្សព្វផ្សាយព័ត៌មានអំពីសុខភាព និងសុវត្ថិភាពការងារ ក្នុងអាជីវកម្មរ៉ែ និងត្រូវរៀបចំស្របទៅតាមបទដ្ឋាន របស់អង្គការអន្តរជាតិខាងការងារ។ |
| ៤.៣-កំណត់មុខរបរ ដែលមានហានិភ័យខ្ពស់និងផ្តល់វិធានការការពារពិសេស | - គ្រប់សហគ្រាស គ្រឹះស្ថានដែលប្រើសារធាតុអាសបេស្តុស និងសារធាតុគីមីគ្រោះថ្នាក់ ទាំងអស់ចាំបាច់ត្រូវចុះបញ្ជីការឱ្យបានត្រឹមត្រូវ ហើយត្រូវបង្កើតឱ្យមាននីតិវិធីសម្រាប់កាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ទាំងនោះ | - ជំរុញការប្រមូលព័ត៌មានតាមរយៈមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត អំពីមុខរបរដែលមានហានិភ័យខ្ពស់ និងធ្វើផែនទីបង្ហាញអំពីទីតាំងនៃមុខរបរទាំងនោះ<br>- ចូលរួមចងក្រង និងផ្សព្វផ្សាយកម្រងព័ត៌មានជាតិស្តីពីសារធាតុអាសបេស្តុស<br>- បណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពការងារ ជាក់លាក់លើមុខរបរដែលមានហានិភ័យខ្ពស់ដល់មន្ត្រីអធិការកិច្ច និយោជក និងកម្មករនិយោជិត ។ | - កន្លែងធ្វើការដែលមានហានិភ័យខ្ពស់នឹងត្រូវកំណត់ និងចាត់វិធានការការពារសមស្រប<br>- កម្រងព័ត៌មានជាតិស្តីពីអាសបេស្តុសត្រូវបានចងក្រង និងផ្សព្វផ្សាយ<br>- មន្ត្រីអធិការកិច្ច និយោជក និងកម្មករនិយោជិតត្រូវបាន បណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពការងារ ជាក់លាក់លើមុខរបរដែលមានហានិភ័យខ្ពស់។ |

## គោលបំណងទី៥៖ ជំរុញឱ្យមានការការពារផ្នែកសុខភាព និងសុវត្ថិភាពការងារ ដល់សហគ្រាសខ្នាតតូច និងមធ្យម និងកន្លែងធ្វើការនៅតាមជនបទ និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ៥.១- ពង្រីកកម្មវិធី បណ្តុះបណ្តាលស្តីពីការកែលម្អរបៀបធ្វើការងារនៅតាមសហគ្រាសខ្នាតតូច និងមធ្យម | - អ្នកធ្វើការក្នុងសហគ្រាសខ្នាតតូច និងមធ្យម ដែលប្រឈមមុខនឹងហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពការងារ ត្រូវការជំនួយសម្រាប់ធ្វើការកែលម្អលក្ខខណ្ឌធ្វើការងារឱ្យកាន់តែល្អប្រសើរ<br>- ការបណ្តុះបណ្តាលស្តីពីការកែលម្អរបៀបធ្វើការងារនៅតាមសហគ្រាសខ្នាតតូច និងមធ្យម មិនបានអនុវត្តបានទូលំទូលាយ | - បន្តបណ្តុះបណ្តាលមន្ត្រីអធិការកិច្ច និងយុវជនស្ម័គ្រចិត្តឱ្យក្លាយទៅជាគ្រូបង្គោលសម្រាប់កម្មវិធីកែលំអលក្ខខណ្ឌធ្វើការងារនៅតាមសហគ្រាសខ្នាតតូច (WISE) និងមធ្យម<br>- បន្តជួយអង្គការនិយោជក និងអង្គការកម្មករនិយោជិត ក្នុងការបណ្តុះបណ្តាលស្តីពីការកែលម្អលក្ខខណ្ឌធ្វើការងារនៅតាមសហគ្រាសខ្នាតតូច និងមធ្យម<br>- ចែករំលែកព័ត៌មាន និងបទពិសោធន៍នៃការអនុវត្តល្អៗ ស្តីពី កម្មវិធីកែលម្អរបៀបធ្វើការរបស់អង្គការអន្តរជាតិខាងការងារជាមួយអាស៊ានអូស្ត្រាលី | - មន្ត្រីអធិការកិច្ច និងយុវជនស្ម័គ្រចិត្ត និងត្រូវបានបណ្តុះបណ្តាលទៅជាគ្រូបង្គោលនៃកម្មវិធីកែលម្អលក្ខខណ្ឌធ្វើការងារនៅតាមសហគ្រាសខ្នាតតូច និងមធ្យម<br>- ការបណ្តុះបណ្តាលស្តីពីការកែលម្អលក្ខខណ្ឌធ្វើការងារនៅតាមសហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានអនុវត្តដោយគ្រូបង្គោល និងយុវជនស្ម័គ្រចិត្តដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ<br>- ការអនុវត្តកម្មវិធីកែលម្អការងារ ដែលចំណាយប្រាក់តិចត្រូវបានចែករំលែកជាមួយបណ្តាញសុខភាព និងសុវត្ថិភាពការងារអាស៊ាន។ |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ៥.២-ពង្រីកកម្មវិធីបណ្តុះបណ្តាល ស្តីពីការកែលម្អរបៀបធ្វើការងារដើម្បីសុវត្ថិភាពអ្នកប្រកបការងារនៅតាមផ្ទះ (WISH) | - អ្នកប្រកបការងារនៅតាមផ្ទះប្រឈមនឹងហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពការងារមួយចំនួន ហើយត្រូវការជំនួយសម្រាប់ធ្វើការកែលម្អលក្ខខណ្ឌធ្វើការងារឱ្យកាន់តែល្អប្រសើរ<br>- ការបណ្តុះបណ្តាល ស្តីពីការកែលម្អរបៀបធ្វើការងារដើម្បីសុវត្ថិភាពអ្នកប្រកបការងារនៅតាមផ្ទះ មិនទាន់បានទូលំទូលាយ | - បន្តផ្តល់ការបណ្តុះបណ្តាល ដល់អ្នកប្រកបការងារនៅតាមផ្ទះ ស្តីពីការកែលម្អរបៀបធ្វើការងារ ដើម្បីសុវត្ថិភាព<br>- បន្តជួយអង្គការដៃគូ និងស្ថាប័នដែលធ្វើការជាមួយអ្នកប្រកបការងារតាមផ្ទះ ក្នុងការបណ្តុះបណ្តាលស្តីពីការកែលម្អរបៀបធ្វើការងារ ដើម្បីសុវត្ថិភាពអ្នកប្រកបការងារនៅតាមផ្ទះ(WISH)<br>- បង្កើតសម្ភារអប់រំផ្សព្វផ្សាយថ្មីៗផ្នែកសុខភាព និងសុវត្ថិភាពការងារ ដែលងាយស្រួលប្រើប្រាស់ និងចំណាយតិចសម្រាប់អ្នកប្រកបការងារតាមផ្ទះ។ | - អ្នកធ្វើការនៅតាមផ្ទះ អង្គការដៃគូ និងស្ថាប័នដែលធ្វើការជាមួយអ្នកប្រកបការងារតាមផ្ទះ បានទទួលការបណ្តុះបណ្តាល ស្តីពីការកែលម្អរបៀបធ្វើការងារ ដើម្បីសុវត្ថិភាពអ្នកប្រកបការងារនៅតាមផ្ទះ<br>- សម្ភារអប់រំ ផ្សព្វផ្សាយថ្មីៗផ្នែកសុខភាព និងសុវត្ថិភាពការងារសម្រាប់អ្នកប្រកបការងារតាមផ្ទះត្រូវបានបង្កើតនិងផ្សព្វផ្សាយ។ |
| ៥.៣-ពង្រីកកម្មវិធីបណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពការងារសម្រាប់កសិករ និងកម្មករនិយោជិតនៅតាមកសិដ្ឋាននានា (WIND) | - អ្នកប្រកបការងារនៅតាមកសិដ្ឋានប្រឈមនឹងហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពការងារ មួយចំនួន ហើយត្រូវការជំនួយសម្រាប់ធ្វើការកែលម្អលក្ខខណ្ឌធ្វើការងារឱ្យកាន់តែល្អប្រសើរ | - បន្តជួយគ្រូបង្គោលផ្នែកកម្មវិធីកែលម្អលក្ខខណ្ឌធ្វើការងារ និងអភិវឌ្ឍន៍ភូមិដ្ឋានដែលមានស្រាប់ហើយនេះឱ្យរៀបចំការបណ្តុះបណ្តាលស្តីពីការកែលម្អរបៀបធ្វើការងារនិងអភិវឌ្ឍភូមិដ្ឋានបានកាន់តែច្រើនថែមទៀត | - ពង្រីកកម្មវិធីកែលំអលក្ខខណ្ឌធ្វើការងារ និងអភិវឌ្ឍភូមិដ្ឋានដល់ខេត្តនិងភូមិកាន់តែច្រើន |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
| --- | --- | --- | --- |
|  | - ការបណ្តុះបណ្តាល ស្តីពីការកែលម្អរបៀបធ្វើការងារដើម្បីសុវត្ថិភាពអ្នកប្រកបការងារនៅតាមផ្ទះ មិនទាន់បានទូលំទូលាយ<br>- ហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពការងារ កំពុងតែកើនឡើងក្នុងវិស័យកសិកម្ម ហើយកសិករកម្ពុជា ត្រូវការវិធានការការពារ ផ្នែកសុខភាព និងសុវត្ថិភាពការងារជាក់ស្តែង និងខ្លាំងក្លា។ ព្រះរាជាណាចក្រកម្ពុជា មានបទពិសោធន៍ក្នុងការបណ្តុះបណ្តាលអំពីការកែលម្អរបៀបធ្វើការងារនិងអភិវឌ្ឍភូមិដ្ឋាន(WIND) ប្រកបដោយជោគជ័យរួចមកហើយ ដែលគប្បីត្រូវចែករំលែក និងពង្រីកសកម្មភាពថែមទៀត ។ | - បន្តបង្កើតឱ្យមានសម្ភារផ្សព្វផ្សាយព័ត៌មាន និងឯកសារបណ្តុះបណ្តាល ដែលងាយយល់ស្តីពីកម្មវិធីកែលម្អរបៀបធ្វើការងារ និងអភិវឌ្ឍន៍ភូមិដ្ឋាន (ដូចជា រូបថត រឿងទាក់ទងការទទួលបានជោគជ័យ និងកូនសៀវភៅផ្សព្វផ្សាយជាដើម)<br>- រួមសហការជាមួយអង្គការនិយោជក និងអង្គការកម្មករនិយោជិតព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពង្រីកការបណ្តុះបណ្តាលស្តីពីកម្មវិធីកែលម្អរបៀបធ្វើការងារ និងអភិវឌ្ឍភូមិដ្ឋាន។ | - គំរូឧទាហរណ៍អំពីការកែលម្អដែលចំណាយប្រាក់តិចជាច្រើនត្រូវបានបង្កើតឡើង និងចែករំលែកយ៉ាងទូលំទូលាយ<br>- កម្មវិធីកែលំអរបៀបធ្វើការងារ និងអភិវឌ្ឍភូមិដ្ឋាន(WIND) ត្រូវបានបញ្ជ្រាបនៅថ្នាក់ខេត្តដើម្បីផ្តល់ការគាំទ្រដល់គ្រូបង្គោល។ |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
| --- | --- | --- | --- |
| ៥.៤- ជំរុញឱ្យមានការបណ្តុះបណ្តាលស្តីពីការកែលំអការងារ និងអភិវឌ្ឍភូមិដ្ឋានសម្រាប់យុវជន (WINDY) | - ការការពារបរិស្ថាន និងការអភិវឌ្ឍសហគមន៍គឺជាការចូលរួមរបស់ប្រជាជន ទាំងអស់គ្នា ជាពិសេសគឺការចូលរួមពីស្រទាប់យុវវ័យពិតជាមានសារៈសំខាន់ណាស់។ | - បណ្តុះបណ្តាលគ្រូបង្គោលផ្នែកកម្មវិធីការកែលំអការងារ និងអភិវឌ្ឍភូមិដ្ឋានសម្រាប់យុវជន (WINDY)<br>- បង្កើតឱ្យមានសម្ភារផ្សព្វផ្សាយព័ត៌មាន និងឯកសារបណ្តុះបណ្តាលដែលងាយយល់ស្តីពីកម្មវិធីកែលម្អរបៀបធ្វើការងារ និងអភិវឌ្ឍភូមិដ្ឋាន (ដូចជា រូបថត រឿងទាក់ទងការទទួលបានជោគជ័យ និងកូនសៀវភៅផ្សព្វផ្សាយជាដើម)<br>- រួមសហការជាមួយសាលារៀន (បឋមសិក្សា និងអនុវិទ្យាល័យ) សហគមន៍ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពង្រីកការបណ្តុះបណ្តាលស្តីពី កម្មវិធីការកែលម្អរបៀប ធ្វើការងារ និងអភិវឌ្ឍភូមិដ្ឋានសម្រាប់យុវជន (WINDY)។ | - កម្មវិធីការកែលម្អលក្ខខណ្ឌធ្វើការងារ និងអភិវឌ្ឍភូមិដ្ឋានសម្រាប់យុវជន (WINDY) បានទៅដល់គ្រប់គោលដៅ<br>- គំរូឧទាហរណ៍អំពីការកែលម្អដែលចំណាយប្រាក់តិច ជាច្រើនត្រូវបានបង្កើតឡើង និងចែករំលែកយ៉ាងទូលំទូលាយ<br>- កម្មវិធីការកែលម្អរបៀបធ្វើការងារ និងអភិវឌ្ឍភូមិដ្ឋានសម្រាប់យុវជន (WINDY) ត្រូវបានបញ្ជ្រាបនៅថ្នាក់ខេត្ត ដើម្បីផ្តល់ការគាំទ្រដល់គ្រូបង្គោល ។ |

| សកម្មភាព | សមិទ្ធិភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ៥.៥-បន្តចងក្រង និងពង្រីកបណ្តាញជនបង្គោល និងអ្នកអនុវត្តកម្មវិធី ស្តីពី WISCON WIND WINDY WISH និង SMEs | - បណ្តាញជនបង្គោល និងអ្នកអនុវត្តកម្មវិធី WISCON WIND WINDY WISH និង SMEs មិនទាន់មានលក្ខណៈជាប្រព័ន្ធច្បាស់លាស់សម្រាប់ទំនាក់ទំនង។ | - រៀបចំបញ្ជីជនបង្គោល គ្រូបង្គោល អ្នកអនុវត្តកម្មវិធី និងអ្នកដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាលរួច<br>- ពង្រឹងបណ្តាញជនបង្គោលតាមមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ធ្វើការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពជនបង្គោល ទៅលើការរៀបចំ និងអនុវត្តផែនការសកម្មភាពផ្នែកសុខភាព និងសុវត្ថិភាពការងារ។ | - បញ្ជីជនបង្គោល គ្រូបង្គោល អ្នកអនុវត្តកម្មវិធី និងអ្នកដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាលត្រូវបានចងក្រងច្បាស់លាស់<br>- ជនបង្គោលតាមមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានទំនាក់ទំនងល្អ និងមានអ្នកទទួលខុសត្រូវច្បាស់លាស់សម្រាប់អនុវត្តកម្មវិធី WISCON WIND WISH WINDY WISH និង SMEs<br>- ផែនការសកម្មភាព ផ្នែកសុខភាព និងសុវត្ថិភាពការងារ ត្រូវបានអនុវត្ត។ |

**គោលបំណងទី ៦៖ គាំទ្រ និងជំរុញកិច្ចសហការផ្នែកសុខភាព និងសុវត្ថិភាពការងារលើការងារកុមារ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជំងឺឆ្លង និងជំងឺមិនឆ្លងនៅតាមសហគ្រាស គ្រឹះស្ថាន**

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ៦-១. ចូលរួមសហការផ្នែកសុខភាព និងសុវត្ថិភាពការងារលើការងារកុមារ | - ព្រះរាជាណាចក្រកម្ពុជា កំពុងអនុវត្ត ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៧-២០២៥)<br>- កុមារមួយចំនួនកំពុងធ្វើការងារនៅកន្លែងដែលប្រឈមនឹងហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពការងារ<br>- | - ចូលរួមអនុវត្តផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងលុបបំបាត់ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៧-២០២៥)<br>- ចូលរួមចុះធ្វើអធិការកិច្ចការងារលើសហគ្រាស គ្រឹះស្ថានដែលប្រើប្រាស់កុមារ<br>- ខិតខំបន្តកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធសុខភាព និងសុវត្ថិភាពការងារលើការងារកុមារនៅកន្លែងធ្វើការ។<br>- អប់រំផ្សព្វផ្សាយការយល់ដឹងពីសុខភាព និងសុវត្ថិភាពការងារ និងព័ត៌មាននៃការលុបបំបាត់ការងារកុមារនៅកន្លែងធ្វើការតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងក្រុមអធិការកិច្ចការងារ។ | - ផែនការសកម្មភាពផ្នែកសុខភាព និងសុវត្ថិភាពការងារលើការងារកុមារត្រូវបានអនុវត្ត<br>- កម្មករនិយោជិតអាយុពី ១៥ ទៅក្រោម ១៨ឆ្នាំ ត្រូវបានការពារ ហើយហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពការងារត្រូវបានកាត់បន្ថយនៅកន្លែងធ្វើការ<br>- កម្មវិធីអប់រំផ្សព្វផ្សាយផ្នែកសុខភាព និងសុវត្ថិភាពការងារទៅដល់កម្មករនិយោជិតវ័យក្មេង ឬនៅកន្លែងធ្វើការដែលប្រកបដោយគ្រោះថ្នាក់ ត្រូវបានអនុវត្ត។ |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| ៦.២-បន្តជំរុញការអនុវត្តប្រកាសលេខ ០៨៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍នៅតាមកន្លែងធ្វើការ និងគោលនយោបាយពាក់ព័ន្ធផ្សេងៗ | - កិច្ចសហការ និងការចូលរួមអនុវត្តប្រកាសលេខ ០៨៦ ពីសហគ្រាសគ្រឹះស្ថានមិនទាន់បានទូលំទូលាយជាពិសេសមិនទាន់បានអនុវត្តពង្រីកទៅដល់សហគ្រាសខ្នាតតូច និងមធ្យម។ | - បន្តការផ្សព្វផ្សាយ និងជំរុញការអនុវត្តប្រកាសលេខ០៨៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍នៅតាមកន្លែងធ្វើការ និងគោលនយោបាយពាក់ព័ន្ធឱ្យបានត្រឹមត្រូវទៅដល់សហគ្រាសខ្នាតតូច និងមធ្យម សហជីព និងកម្មករនិយោជិត<br>- បន្តធ្វើការលើកទឹកចិត្តដល់សហគ្រាស គ្រឹះស្ថានដែលបានអនុវត្តល្អ។ | - គណៈកម្មការអេដស៍នៅតាមសហគ្រាសគ្រឹះស្ថាន និងការទប់ស្កាត់មេរោគអេដស៍នៅតាមកន្លែងធ្វើការត្រូវបានបង្កើត និងដំណើរការ<br>- កម្មករនិយោជិតដែលមានផ្ទុកមេរោគអេដស៍ ត្រូវបានគាំពារដោយគោលនយោបាយអេដស៍ប្រចាំសហគ្រាស។ |

| សកម្មភាព | សនិទានភាព | យុទ្ធសាស្ត្រ | ចំណុចដៅ |
|---|---|---|---|
| **៦.៣- ធ្វើកិច្ចសហប្រតិបត្តិការអនុវត្តគម្រោង ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជំងឺឆ្លង និងជំងឺមិនឆ្លងនៅកន្លែងធ្វើការ** | - កន្លែងធ្វើការភាគច្រើនមិនត្រឹមតែប្រឈមជាមួយនិងបញ្ហាសុខភាព និងសុវត្ថិភាពការងារប៉ុណ្ណោះទេ ប៉ុន្តែមានការប្រឈមជាមួយនឹងគ្រឿងញៀន ជំងឺឆ្លង និងជំងឺមិនឆ្លង។ ដូចនេះតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការជាមួយគម្រោងរបស់ក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍដើម្បីធានាឱ្យកន្លែងធ្វើការមានសុខភាព និងសុវត្ថិភាពការងារល្អ | - ជំរុញឱ្យមានកិច្ចសហប្រតិបត្តិការអនុវត្តគម្រោងស្តីពីការបង្ការមេរោគអេដស៍/ជំងឺអេដស៍ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជំងឺឆ្លង និងជំងឺមិនឆ្លងនៅកន្លែងធ្វើការ<br>- បន្តស្វែងរកជំនួយពីដៃគូក្នុងការអភិវឌ្ឍកម្មវិធីប្រយុទ្ធប្រឆាំងគ្រឿងញៀនជំងឺឆ្លង និងជំងឺមិនឆ្លងនៅកន្លែងធ្វើការ<br>- ចូលរួមអនុវត្តកម្មវិធី ឬយុទ្ធនាការផ្សព្វផ្សាយ ប្រយុទ្ធប្រឆាំងគ្រឿងញៀន និងទប់ស្កាត់ជំងឺឆ្លង និងជំងឺមិនឆ្លងនៅកន្លែងធ្វើការ<br>- បញ្ជ្រាបកម្មវិធីសុខភាព និងសុវត្ថិភាពការងារទៅក្នុងយុទ្ធនាការ ឬសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនជំងឺឆ្លង និងជំងឺមិនឆ្លងនៅកន្លែងធ្វើការ។ | - សកម្មភាពសហប្រតិបត្តិការ ត្រូវបានអនុវត្ត<br>- ផែនការសកម្មភាពរួមគ្នាស្តីពីការបង្ការមេរោគអេដស៍/ជំងឺអេដស៍ និងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជំងឺឆ្លងនិងជំងឺមិនឆ្លងនៅកន្លែងធ្វើការត្រូវបានអនុវត្ត<br>- យុទ្ធនាការ ឬកម្មវិធី របស់ក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក (WHO) និងអង្គការដៃគូអភិវឌ្ឍត្រូវបានផ្សព្វផ្សាយ<br>- កម្មវិធីសុខភាព និងសុវត្ថិភាពការងារត្រូវបានបញ្ជ្រាបទៅក្នុងយុទ្ធនាការឬសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនជំងឺឆ្លង និងជំងឺមិនឆ្លងនៅកន្លែងធ្វើការត្រូវបានបញ្ជ្រាប។ |

## ទីប្រឹក្សា និងក្រុមការងាររៀបចំ

**ទីប្រឹក្សា៖**

| | | |
|---|---|---|
| ១. ឯកឧត្តមវេជ្ជ. | **ហ៊ុយ ហានសុខ** | រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២. លោកជំទាវ | **ជា សុខនី** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៣. លោក | **ទុន សោភ័ណ** | អ្នកសម្របសម្រួលថ្នាក់ជាតិនៃអង្គការអន្តរជាតិខាងការងារប្រចាំប្រទេសកម្ពុជា |
| ៤. លោកស្រី | **ប៉ោ ជួន** | អ្នកសម្របសម្រួលគម្រោងលើកកម្ពស់ស្តង់ដាសុខភាព និងសុវត្ថិភាពការងារក្នុងវិស័យសំណង់នៃអង្គការអន្តរជាតិខាងការងារ |

**ក្រុមការងារនៃនាយកដ្ឋានពេទ្យការងារ៖**

| | | |
|---|---|---|
| ១. ឯកឧត្តមទន្ត. | **ឡេង តុង** | ទីប្រឹក្សាអមក្រសួង និងជាប្រធាននាយកដ្ឋាន |
| ២. ឯកឧត្តមវេជ្ជ. | **យី កន្និដ្ឋា** | ទីប្រឹក្សាអមក្រសួង និងជាអនុប្រធាននាយកដ្ឋាន |
| ៣. ឯកឧត្តមវេជ្ជ. | **ខុន ណារិទ្ធ** | អនុប្រធាននាយកដ្ឋាន |
| ៤. លោក | **ជួន អាននីដា** | អនុប្រធាននាយកដ្ឋាន |
| ៥. លោកវេជ្ជ. | **ហាន់ នព្វគុណ** | អនុប្រធាននាយកដ្ឋាន |
| ៦. លោកស្រីវេជ្ជ. | **ពេជ្រ ស្លាសិរី** | អនុប្រធាននាយកដ្ឋាន |
| ៧. លោកវេជ្ជ. | **ខាន់ តុលា** | អនុប្រធាននាយកដ្ឋាន |
| ៨. លោក | **សុខ សុស្សា** | អនុប្រធាននាយកដ្ឋាន |
| ៩. លោកវេជ្ជ. | **កែវ ធួន** | អនុប្រធាននាយកដ្ឋាន |
| ១០. លោកវេជ្ជ. | **គង់ វឌ្ឍនា** | ប្រធានការិយាល័យ |
| ១១. លោកស្រី | **ម៉ិះ ចាន់ថ្លា** | ប្រធានការិយាល័យ |
| ១២. លោកស្រីឱ.ការី | **តាន់ ឥស្សរាវរដ្ឋ** | ប្រធានការិយាល័យ |

| | | |
|---|---|---|
| ១៣.លោកស្រីឱ.ការី | **គង់ សត្យា** | ប្រធានការិយាល័យ |
| ១៤.លោកស្រី | **កែ ថេរះមុនី** | ប្រធានការិយាល័យ |
| ១៥.លោក | **អូច ប៊ុនធឿន** | ប្រធានការិយាល័យ |
| ១៦.កញ្ញាវេជ្ជ. | **ស៊ុន រដ្ឋា** | ប្រធានការិយាល័យ |
| ១៧.លោក | **អែម ចណ្ណា** | ប្រធានការិយាល័យ |